សមាគម "ជួយស្រុកកំណើតយើង" គឺជាអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងមិនជាប់ពាក់ព័ន្ធនឹងនយោបាយ ហើយគឺជាសមាគមដែលបង្កើតឡើងតាមរយៈការសំរេចចិត្តដោយសេរី ដោយយកអត្ថប្រយោជន៍រួមជាគោលសំរាប់អ្នកមកពីខេត្តដូចគ្នា។

សមាគមត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤។




អាសយដ្ឋាន:

ភ្នំពេញ: ផ្ទះលេខ ៤៣ ស្ទួន ក្រុមទី ៥ ភូមិសន្សំកុសល ២សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Tel: 016 715 415, 012 98 69 69

នៅខេត្តកំពង់ធំ: ផ្ទះលេខ១៤៩ ក្រុម៣០ ភូមិស្ទឹងសែន ឃុំកំពង់ក្របៅ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ព្រះរាជាណាចក្រកម្ពុជា
Tel: 012 95 26 46, 012 87 79 79
E-mail: hoh_association@yahoo.com


HOH

# ជួយស្រុកកំណើតយើង

## ជ.ស.យ

## Help Our Homeland

**ការចូលរួមចំណែករបស់អ្នក**

**គឺ**

**ជួយស្រុកកំណើតយើង !**

**ជួយស្រុកកំណើតយើង**

**គឺ**

**ជួយប្រទេសជាតិយើង !**

## ទស្សនៈវិស័យ :

ទស្សនៈវិស័យរបស់សមាគមគឺ "ភាពចំរុងចំរើនក្នុងស្រុកកំណើតយើងតាមរយៈបណ្តាញក្រុមការងារយើង"

## បេសកកម្ម :

ចងក្រងបណ្តាញអ្នកដែលមកពីខេត្តស្រុកកំណើតជាមួយគ្នាដើម្បីជួយអភិវឌ្ឍស្រុកកំណើតខ្លួន និងដើម្បីបង្កើនសាមគ្គីភាពរវាងគ្នា និងគ្នា។

## តម្លៃចំបង :

ធ្វើខ្លួនឱ្យទៅជាអង្គភាពមួយដែលទទួលបាននូវការពេញចិត្តបំផុតពីសង្គម និងអ្នកពាក់ព័ន្ធតាមរយៈ:

-សេចក្តីស្រលាញ់

-សេចក្តីមេត្តាករុណា

-សាមគ្គីភាព

## គោលដៅ និងសកម្មភាពការងារ :

១. ការពង្រឹងសមត្ថភាព និងការបង្កើតបណ្តាញក្រុមការងារ

២. ការលើកទឹកចិត្តដល់ការអប់រំ និងផ្នែកកីឡានៅតាមវិទ្យាល័យនានា

៣. ពង្រឹងសមត្ថភាពធនធានមនុស្សសំរាប់ការអភិវឌ្ឍន៍សហគមន៍តាមមូលដ្ឋាន

៤. ការបង្កើតការអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន

# បុព្វហេតុនៃការកើតសមាគម

មនុស្សមួយចំនួនបានឃ្លាតចាកឆ្ងាយពីភូមិស្រុក ទៅនៅកន្លែងថ្មីមួយ ឬចាកចេញទៅកាន់ប្រទេសថ្មីមួយទៀតដើម្បីបំពេញការរៀនសូត្រ ឬប្រកបមុខរបរសម្រាប់អនាគតដ៏ភ្លឺស្វាងរបស់ខ្លួន។ គេសង្កេតឃើញភាគច្រើនពួកគេទាំងនោះមិនបាន វិលត្រលប់ទៅស្រុកកំណើតរបស់ខ្លួនវិញទេ ដោយសារតែទីនោះមិនបានផ្តល់ឱកាសការងារ និងមុខរបរចិញ្ចឹមជីវិតដល់ពួកគេ។

តែទោះជាទៅដល់ទីណាក៏ដោយ ពួកគេតែងតែនឹកឃើញដល់ភូមិស្រុក ដែលជាកន្លែងផ្តល់កំណើតជាកន្លែងដែល គេធំដឹងក្តីជាកន្លែង ដែលប្រជុំទៅដោយសាច់ញាតិ បងប្អូន មិត្តភ័ក្តិ និងជាកន្លែងដែលបន្សល់ទុកនូវអនុស្សាវរីយ៍យ៉ាងច្រើនរាប់មិនអស់។ ម្យ៉ាងទៀត សេចក្តីស្រលាញ់ និងការនឹករលឹកដល់ស្រុកកំណើតជារឿងមួយដែលមិនអាចភ្លេចបាននៅក្នុងជីវិតរបស់គេ។ លើសពីនេះទៅទៀតនោះ ការអភិវឌ្ឍន៍ស្រុកកំណើត ការចង់ឃើញស្រុកកំណើតរីកចំរើនលូតលាស់ និងការរួមចំណែកជួយដល់ស្រុកកំណើតតែងមានជានិច្ចនៅក្នុងចិត្តគំនិតរបស់ពួកគេ។ បើយើងក្រលេកមើលទៅអតីតកាលវិញ យើងឃើញថា ប្រទេសកម្ពុជាធ្លាប់ជាមហានគរដ៏ល្បីល្បាញមួយនៅក្នុងតំបន់ នាសម័យអង្គរដ៏រុងរឿង។ ជាអកុសល ដោយសារការបែកបាក់សាមគ្គីគ្នា និងសង្គ្រាមរ៉ាំរ៉ៃ ដែលបានកើតឡើងជាបន្តបន្ទាប់បាន ធ្វើឱ្យប្រទេសកម្ពុជាធ្លាក់ចុះកិត្យានុភាពរបស់ខ្លួនបន្តិចម្តងៗ។




ជាពិសេស ឆ្លងកាត់សង្គ្រាមស៊ីវិលជាងពីរទសវត្សចុងក្រោយនេះ រឹតតែធ្វើឱ្យសង្គមខ្មែរកាន់តែធ្លាក់ចុះដុនដាប រហូតត្រូវបានគេចាត់ទុកថាជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុតលើពិភពលោក។ បទពិសោធន៍ដ៏អាក្រក់នេះបានបន្សល់ទុកឱ្យសង្គមខ្មែរបច្ចុប្បន្ននូវបញ្ហាជាច្រើនដូចជា:

-មានការបាត់បង់ភាពទុកចិត្តគ្នា សេចក្តីស្រលាញ់ សាមគ្គីភាព និងមេត្តាករុណា

-មានការធ្លាក់ចុះលើផ្នែកសីលធម៌សង្គមគួរឱ្យកត់សំគាល់

-មានកង្វះខាតផ្នែកធនធានមនុស្សទាំងសមត្ថភាព និងជំនាញ ហើយគុណភាពអប់រំនៅមានកំរិតទាប ជាពិសេសធនធានមនុស្សនៅតាមបណ្តាខេត្តសំរាប់អភិវឌ្ឍសហគមន៍ ដែលជាមូលដ្ឋានចំបងក្នុងការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូល។

ដើម្បីចូលរួមចំណែកក្នុងការស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិយើងឡើងវិញ និងដើម្បីឆ្លើយតបទៅ នឹងបញ្ហាខាងលើ ព្រមទាំងដើម្បីឱ្យអ្នកដែលមានគំនិតចង់ជួយស្រុកកំណើតបានសម្រេចតាមគោលបំណងរបស់ខ្លួនយើងទាំងអស់គ្នាបានផ្តួចផ្តើមបង្កើតជាសមាគមមួយដែលមានឈ្មោះថា "ជួយស្រុកកំណើតយើង"។

# “ជួយស្រុកកំណើតយើង”

**សមាជិករបស់សមាគម :**

មានពីរប្រភេទគឺ

សមាជិកសកម្ម និងសមាជិកកិត្តិយស

-សមាជិកសកម្មគឺជាម្ចាស់ជំនួយទាំងឡាយណាដែលផ្តល់វិភាគទានដោយស្ម័គ្រចិត្តជាប្រចាំដល់សមាគម ឬចូលរួមក្នុងសកម្មភាពរបស់សមាគមដោយផ្ទាល់។

-សមាជិកកិត្តិយសជាម្ចាស់ជំនួយទាំងឡាយណាដែលធ្លាប់បានផ្តល់វិភាគទានដោយស្ម័គ្រចិត្តដល់សមាគម ឬចូលរួមគាំទ្រដល់សកម្មភាពសមាគម។